ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១១ លេខ ២ | មេសា - មិថុនា ឆ្នាំ២០០៧ | តម្លៃ ១.៥០០៛

## សន្និសីទចក្ខុវិស័យកម្ពុជាឆ្នាំ២០០៧: ចក្ខុវិស័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ការពន្លឿនការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងចំណូលពីប្រេងកាត និងឧស្ម័នធម្មជាតិ

នៅថ្ងៃទី២២-២៣ កុម្ភៈ ២០០៧ វិទ្យាស្ថាន CDRI ដោយរួមសហការជាដៃគូជាមួយ ធនាគារ ANZ Royal បានរៀបចំធ្វើសន្និសីទចក្ខុវិស័យកម្ពុជាឆ្នាំ២០០៧ នៅក្រុងភ្នំពេញ ។ សន្និសីទនេះមានការអញ្ជើញចូលរួម ពីសំណាក់ថ្នាក់ដឹកនាំជាង ២០០នាក់ មកពីរដ្ឋាភិបាល អាជីវកម្ម អង្គការសង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ ដើម្បីពិភាក្សាពីបញ្ហាគន្លឹះៗរបស់កម្ពុជាទាក់ទិននឹងកំណើន ការអភិវឌ្ឍន៍ និងវិបុលភាព ។ សន្និសីទនេះ ដែលនឹងប្រារព្ធធ្វើជារៀងរាល់ឆ្នាំ មានបែងចែកជា ៦វគ្គ:



ប្រទេសកម្ពុជាមានតំបន់ប្រេងកាតនៅបាតសមុទ្រ ៦កន្លែង និងតំបន់សម្បទានត្រួតគ្នាមួយ (OCA)

- កម្ពុជាឆ្នាំ២០០៧: ទិដ្ឋភាពម៉ាក្រូ - សូចនាករសំខាន់ៗនៃ កំណើន ការអភិវឌ្ឍន៍ និងវិបុលភាពរួម
- កម្ពុជាក្នុងចំណោមប្រទេសជិតខាងដែលមានកំណើន និងកាលានុវត្តភាព: ទស្សនវិស័យរបស់អ្នកជំនាញការមកពីចិន ថៃ និងវៀតណាម
- ការពង្រឹងពង្រីកក្បាលម៉ាស៊ីនកំណើន និងអភិវឌ្ឍន៍: ហិរញ្ញវត្ថុ ទីផ្សារវិស័យឯកជន និងវិនិយោគផ្ទាល់ពីបរទេស
- ការចេញពីការពឹងផ្អែកលើជំនួយឆ្ពោះទៅកាន់វិបុលភាពរួម: ការគ្រប់គ្រងធនធានប្រេងកាត និងឧស្ម័នរបស់កម្ពុជា
- ការប្រយុទ្ធនឹងភាពក្រីក្រ: ដល់ពេលអនុវត្តសកម្មភាពមានកំណត់គោលដៅច្បាស់លាស់
- ទស្សនវិស័យ និងមាគ៌ាឆ្ពោះទៅមុខ

សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានលើកនៅក្នុងសុន្ទរកថាគន្លឹះបើកសន្និសីទថា:

*"ខ្ញុំសូមគូសបញ្ជាក់ថា ការពិភាក្សាយ៉ាងយកចិត្តទុកដាក់នៅក្នុងសន្និសីទនេះ ជាពិសេសការផ្ដល់នូវគំនិតល្អៗ និងយោបល់ជាក់ស្ដែងប្រកបដោយនិម្មាបនកម្ម នឹងរួមចំណែកជួយសម្រួលដល់ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងរួមចំណែកសម្រួលដល់ការសម្រេចនៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាផងដែរ ។"*

*"ខ្ញុំសង្ឃឹមថា អ្នកចូលរួមទាំងអស់នឹងផ្ដល់គំនិតល្អៗស្ដីពីការកសាងសេដ្ឋកិច្ចឱ្យមានកំណើនប្រកបដោយចីរភាព ដើម្បីចែករំលែកផ្លែផ្កានៃការអភិវឌ្ឍន៍ប្រកបដោយសមភាព និងលើកកំពស់ការិតជីវភាពប្រជាជនកម្ពុជានៅគ្រប់ស្រទាប់សង្គម ។"*

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* លេខនេះមានចុះផ្សាយជាពិសេសនូវបទបង្ហាញគន្លឹះមួយចំនួនក្នុងសន្និសីទចក្ខុវិស័យកម្ពុជាលើកទី១ ។ បទបង្ហាញឯទៀត រួមទាំងសុន្ទរកថាទាំងស្រុងរបស់សម្ដេចនាយក មានចុះក្នុងវេបសាយរបស់ CDRI ។

### មាតិកា

សន្និសីទចក្ខុវិស័យកម្ពុជា ........ ១
កម្ពុជា: ការពិនិត្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ចពីឆ្នាំ២០០៧ ........ ២
ចេញពីការពឹងផ្អែកលើជំនួយ ឆ្ពោះទៅកាន់វិបុលភាពរួម ........ ៥
បង្កើនល្បឿនការកាត់បន្ថយភាពក្រីក្រ ........ ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៦
— ស្ថានភាពក្នុងប្រទេស ........ ១៥
— សន្ទស្សន៍សេដ្ឋកិច្ច ........ ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២៤